# សេចក្តីព្រាងសន្ទរកថា
# ឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
# ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបការងារក្រសួងពាណិជ្ជកម្ម ឆ្នាំ២០០៩
# និង លើកទិសដៅការងារឆ្នាំ២០១០

ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០

*-ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម*

*-ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ អន្តរជាតិ*

ថ្ងៃនេះ ខ្ញុំមានកិត្តិយស និង សេចក្តីសោមនស្សរីករាយជាអនេក ដោយបានចូលរួមជាអធិបតីក្នុងពិធីបើកអង្គសន្និបាតប្រចាំឆ្នាំរបស់ក្រសួងពាណិជ្ជកម្ម ដែលបានរៀបចំឡើងដើម្បីបូកសរុបការងារពាណិជ្ជកម្ម ឆ្នាំ២០០៩ និងលើកទិសដៅការងារពាណិជ្ជកម្មឆ្នាំ២០១០ តាមការអញ្ជើញរបស់ ឯកឧត្តមបណ្ឌិត ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

សន្និបាតរបស់ក្រសួងពាណិជ្ជកម្មនាឆ្នាំនេះ គឺជាការបូកសរុបការងារឆ្នាំទី២ **នៃការអនុវត្តន៍យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២** ដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានប្រកាសដាក់ឱ្យអនុវត្តក្នុងរាជរដ្ឋាភិបាលនៃនីតិកាលទី៣ នៃរដ្ឋសភា ។

ខ្ញុំសូមឆ្លៀតយកឱកាសនេះ សំដែងនូវការកោតសរសើរដោយស្មោះអស់ពីចិត្ត និងសូមវាយតម្លៃខ្ពស់ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ និងមន្ត្រីរាជការក្រោមឱវាទក្រសួងពាណិជ្ជកម្មទាំងអស់ ក្នុងការខិតខំបំពេញការងាររបស់ខ្លួន ក្នុងទិសដៅជំរុញវិស័យពាណិជ្ជកម្ម ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលហើយទទួលបាននូវលទ្ធផលល្អគួរជាទីមោទនៈនៅក្នុងឆ្នាំកន្លងមកនេះ។ ខ្ញុំសូមកោតសរសើរ ជាពិសេស ឯកឧត្តមបណ្ឌិត ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដែលបានបម្រើការងារក្នុងវិស័យនេះ ប្រកបដោយប្រសិទ្ធភាព និង ឧត្តមភាព ខ្ពង់ខ្ពស់ ព្រមទាំងសម្រេចបានលទ្ធផលជាផ្លែផ្កាជាច្រើន ជូនប្រទេសជាតិ។ ភស្តុតាងធំៗពីរ គឺ *ការចូលជា សមាជិកតំបន់ពាណិជ្ជកម្មសេរីអាស៊ាន* និង *ការចូលជាសមាជិកអង្គការពាណិជ្ជកម្ម ពិភពលោក*។

ក្នុងវិស័យកំណែទម្រង់ក្រសួងត្រូវបានរាជរដ្ឋាភិបាលប្រគល់ភារកិច្ច ឱ្យដឹកនាំកិច្ចសម្រួលពាណិជ្ជកម្ម ជាផ្នែកមួយនៃកំណែទម្រង់របស់រាជរដ្ឋភិបាល ដែលក្នុងនោះ ការងារអភិវឌ្ឍន៍ពាណិជ្ជកម្ម និង ការសម្រួលពាណិជ្ជកម្ម បានទទួលនូវជោគជ័យគួរឱ្យកោតសរសើរ ដោយបានដាក់ឱ្យអនុវត្តប្រព័ន្ធ ASYCUDA នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ និង

នៅផែស្ទួត។ ដោយឡែកក្រសួង ក៏បានចូលរួមចំណែក ក្នុងកំណែទម្រង់ច្បាប់ និងតុលាការ ដោយអនុវត្តបានល្អប្រសើរ ក្នុងការអនុវត្តនីតិគំរោង **ផ្នែកតម្លាភាពនៃច្បាប់** ដោយបានបណ្តុះបណ្តាលចៅក្រម នៅដើម ខែតុលា ឆ្នាំ២០០៩ អំពីការប្រើប្រាស់ និង ការគ្រប់គ្រងគេហទំព័រ និងបានរៀបចំបង្កើតគេហទំព័រ០២ នៅឯក្រសួងយុត្តិធម៌ និងតុលាការកំពូល និងការកែទម្រង់គេហទំព័រដែលមានស្រាប់ របស់ក្រសួងពាណិជ្ជកម្ម។ នៅចុងខែសីហា ឆ្នាំ២០០៩ គេហទំព័រសំរាប់ក្រសួងយុត្តិធម៌ និង តុលាការកំពូល បានដំណើរការដោយជោគជ័យ។

សន្និបាតនាពេលនេះ គឺជាឱកាសមួយដ៏ល្អ សម្រាប់យើងទាំងអស់គ្នាធ្វើការពិចារណាបូកសរុបលទ្ធផល ការងារ និងដកបទពិសោធន៍ក្នុងឆ្នាំកន្លងទៅ ហើយស្វែងរកនូវវិធានការណ៍ថ្មីៗ ល្អៗ ដើម្បីបន្តជំរុញការ អភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គមកម្ពុជា បង្កើតបរិយាកាសពាណិជ្ជកម្មឱ្យកាន់តែបានច្រើន និង ល្អប្រសើរ និង រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

**-ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវជាតិ អន្តរជាតិ !**

ចាប់ពីឆ្នាំ ២០០៤-២០០៧ កម្ពុជាមានកំណើនសេដ្ឋកិច្ចយ៉ាងតិច ១០% ដែលជាកំណើនមួយខ្ពស់ សំរាប់កម្ពុជា និង នៅក្នុងតំបន់។ នៅឆ្នាំ២០០៥ កម្ពុជាសំរេចបាននូវកំនើនសេដ្ឋកិច្ចខ្ពស់បំផុតគឺ ១៣,៣%។ នៅឆ្នាំ២០០៨ កំណើនសេដ្ឋកិច្ចបានថយមកនៅត្រឹម ៦,៨% ហើយនៅឆ្នាំ២០០៩ កំណើននេះ បានថយមកនៅត្រឹម ២% ដោយសារតែវិបត្តិសេដ្ឋកិច្ច និង ហិរញ្ញវត្ថុពិភពលោក ដែលបានចាប់ផ្តើម នៅក្នុងប្រទេសអភិវឌ្ឍន៍នៅចុងឆ្នាំ២០០៧។ នៅឆ្នាំ២០១០ នេះ យើងសង្ឃឹមថា កម្ពុជានឹងមានកំណើនសេដ្ឋកិច្ចខ្ពស់ជាងឆ្នាំកន្លងទៅ។ ជាមួយនេះ អត្រាអតិផរណាប្រចាំឆ្នាំ២០០៩ បានចុះមកនៅត្រឹមតែ ៥,៣% ប៉ុណ្ណោះ នៅពេលដែលអតិផរណាប្រចាំឆ្នាំ២០០៨ មានរហូតដល់ទៅ ១២,៥% នេះគឺដោយសារតែថ្លៃប្រេងឥន្ធនៈខ្ពស់។

ដើម្បីរួមចំណែកជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ និងកសាងបន្ថែមលើខឿនដ៏រឹងមាំដែលមានស្រាប់ ជាពិសេសក្នុងបរិការនៃវិបត្តិសេដ្ឋកិច្ចពិភពលោកដែលពុំទាន់ងើបផុតទាំងស្រុងនោះ ក្រសួងពាណិជ្ជកម្មគប្បីដើរតួនាទីកាន់តែសកម្មថែមទៀត ជំនះឱ្យបានលើបញ្ហាប្រឈមមុខជាច្រើនក្នុងវិស័យពាណិជ្ជកម្មជាតិ និង អន្តរជាតិ។ ដូច្នេះអង្គសន្និបាតត្រូវយកចិត្តទុកដាក់ពិភាក្សារកឱ្យឃើញបញ្ហាគន្លឹះទាំងឡាយក្នុងការលើកកំពស់ពាណិជ្ជកម្មជាតិ និង អន្តរជាតិ រួចដាក់ចេញជាវិធានការណ៍នានា ឈានទៅដោះស្រាយបញ្ហាប្រឈមមុខទាំងនោះ នៅក្រោមក្របខ័ណ្ឌ "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី២**" របស់រាជរដ្ឋាភិបាល។

ខ្ញុំសូមលើកយកបញ្ហាមួយចំនួនដូច ខាងក្រោម ដែលតម្រូវឱ្យមានការគិតគូរឱ្យបានហ្មត់ចត់ :

**ទី១- ការប្រើប្រាស់ប្រពន្ធ័អនុគ្រោះពាណិជ្ជកម្ម និង ពង្រីកទីផ្សារសម្រាប់ផលិតផលកម្ពុជា**

កម្ពុជា ជាប្រទេសដែលអភិវឌ្ឍន៍តិចតួច បានទទួលនូវការអនុគ្រោះពន្ធនាំចូល សំរាប់ផលិតផលកម្ពុជា ពីប្រទេសអភិវឌ្ឍន៍ និង ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ដូចជាៈ សហរដ្ឋអាមេរិក សហភាពអឺរ៉ុប កាណាដា ជប៉ុន អូស្ត្រាលី ចិន កូរ៉េ ។ល។ ជាមួយនេះ យើងមានទីផ្សារអនុគ្រោះពន្ធនាំចូលដែលទទួលបានពីកិច្ចសហប្រតិបត្តិការក្នុងតំបន់អាស៊ាន

និងជាមួយដៃគូរបស់អាស៊ាន ក៏ដូចជាទីផ្សារដែលទទួលបានក្នុងក្របខ័ណ្ឌ អង្គការពាណិជ្ជកម្មពិភពលោក។ ដូចនេះ ការខិតខំជំរុញការប្រើប្រាស់ទីផ្សារទាំងនោះឱ្យបានជាអតិបរមា មានសារៈសំខាន់ណាស់ សំរាប់ការជំរុញពាណិជ្ជកម្ម និង សេដ្ឋកិច្ចកម្ពុជា និង ការកាត់បន្ថយភាពក្រីក្រ។

លើសពីនេះ ការខិតខំបន្តពង្រីកទីផ្សារសំរាប់ផលិតផលកម្ពុជា គឺកិច្ចការមួយដ៏សំខាន់របស់វិស័យពាណិជ្ជកម្ម ហើយដែលកម្ពុជាត្រូវធ្វើជាប្រចាំ ដើម្បីធានានូវភាពប្រកួតប្រជែងរបស់កម្ពុជានៅក្នុងតំបន់។

**ទី២- ការរក្សាស្ថេរភាពថ្លៃទំនិញ និងសន្តិសុខស្បៀង**

ការរក្សាស្ថេរភាពថ្លៃទំនិញប្រើប្រាស់ជាមូលដ្ឋាន ជាពិសេសថ្លៃម្ហូបអាហារសំខាន់ៗ និងប្រេងឥន្ធនៈមានសារៈសំខាន់ណាស់សំរាប់ស្ថេរភាពសង្គម និងការអភិវឌ្ឍន៏ប្រទេស ដូចនេះ ក្រសួងពាណិជ្ជកម្មមានតួនាទីសំខាន់ ក្នុងការបន្តតាមដានតំលៃទំនិញសំខាន់ៗនៅលើទីផ្សារ និងចាត់វិធានការណ៏សមស្រប ដើម្បីទប់ស្កាត់ការឡើងថ្លៃទំនិញទាំងនោះ ដែលអាចកើតមានដោយប្រការណាមួយ។ ជាមួយនេះ ការបន្តចាត់ វិធានការណ៏សមស្រប ដើម្បីរក្សាសន្តិសុខស្បៀង ជាពិសេសអង្ករ ឱ្យប្រកបដោយប្រសិទ្ធិភាពខ្ពស់ វាជាកិច្ចការចាំបាច់បំផុត។

**ទី៣- ការកសាងបញ្ញត្តិច្បាប់ពាណិជ្ជកម្ម និងការរៀបចំ និង ការពង្រីកការអនុវត្តន៏ច្បាប់កម្មសិទ្ធិបញ្ញា ការទប់ស្កាត់ការផលិត ការចែកចាយ ផលិតផលក្លែងបន្លំ ផលិតផលគ្មានគុណភាព ឬខូចគុណភាព**

ដើម្បីឱ្យយន្តការសេដ្ឋកិច្ចទីផ្សារនៅក្នុងប្រទេសមានដំណើរការកាន់តែប្រសើរឡើង និងដើម្បីឆ្លើយតបនឹងការវិវត្តន៏ថ្មីៗនៃសភាពការណ៏ពាណិជ្ជកម្មក្នុងតំបន់ និង ពិភពលោក ក្រសួងពាណិជ្ជកម្មចាំបាច់ត្រូវបន្ត ជំរុញការរៀបចំកសាងច្បាប់ និង បទបញ្ញត្តិនានា ដែលនៅខ្វះចន្លោះឱ្យបានសមស្រប ដើម្បីសំរួល និងផ្តល់ភាពកក់ក្តៅដល់ធុរៈជន និង វិនិយោគគិន ក្នុងការប្រកបអាជីវកម្មនៅក្នុងប្រទេសយើង។ ជាមួយនេះ ការពង្រឹងការអនុវត្តន៏ច្បាប់ និង បទបញ្ញត្តិនានាដែលមានជាធរមាន ក៏ជាការងារចាំបាច់ផងដែរ។

លើសពីនេះយើងត្រូវបន្តទប់ស្កាត់ផលិតផលក្លែងបន្លំ ផលិតផលគ្មានគុណភាព ឬ ខូចគុណភាព ការប្រកួតប្រជែងមិនស្មោះត្រង់ ដើម្បីការពារសុខមាលភាពរបស់ប្រជាជនយើង និង អ្នកប្រើប្រាស់ជារួម។ ចំណុចនេះ ក្រសួងពាណិជ្ជកម្មត្រូវខិតខំលើកកំពស់ឱ្យបានកាន់តែប្រសើរនូវសុវត្ថិភាពម្ហូបអាហារជូនអ្នកប្រើប្រាស់ តាមរយៈវិធានការណ៏សមស្រប ដូចជាការផ្តល់ព័ត៌មានស្តីពីភាពគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងឧបភោគ បរិភោគ ដែលខូចគុណភាព និង ទប់ស្កាត់កុំឱ្យកម្ពុជាទៅកន្លែងប្រើប្រាស់ផលិតផលមិនល្អ ទាំងនោះ។

**ទី៤-ការពង្រឹងវិស័យឯកជន ការទាក់ទាញការវិនិយោគ និងកិច្ចសម្រួលពាណិជ្ជកម្ម**

ការសម្រួលពាណិជ្ជកម្ម គឺជាកិច្ចការមួយដ៏សំខាន់ ដើម្បីកាត់បន្ថយចំណាយ ជាពេលវេលា និង ធនធាន ក្នុងការធ្វើអាជីវកម្ម ដើម្បីបង្កើននូវចំណូល និង ភាពប្រកួតប្រជែងរបស់ក្រុមហ៊ុនជាមួយក្រុមហ៊ុនបរទេស។ ការសម្រួល

ពាណិជ្ជកម្ម ជាការងារមួយ ដែលទាមទារឱ្យមានកិច្ចសហការពីគ្រប់ក្រសួង និង ស្ថាប័នពាក់ពន្ធ័ ដូចជា ក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសាធារណៈការនិងដឹកជញ្ជូន ។ល។ ការខិតខំប្រឹងប្រែងផ្តល់សេវាសាធារណៈឱ្យកាន់តែប្រសើរឡើងគឺវាមានសារៈសំខាន់ណាស់ ដើម្បីថែរក្សាបរិស្ថាន ធុរកិច្ចឱ្យបានល្អ។ ដូចនេះ ក្រសួងពាណិជ្ជកម្មត្រូវបន្តបង្កលក្ខណៈងាយស្រួល ដល់ការផ្តល់វិញ្ញាណបនបត្រ័បញ្ជាក់ប្រភពដើមទំនិញ ការចុះបញ្ជីពាណិជ្ជកម្ម និង ការចុះបញ្ជីពាណិជ្ជសញ្ញា ឱ្យកាន់តែប្រសើរឡើងថែមទៀត ដើម្បីបន្តគាំទ្រដល់វិសយ័ឯកជន ជាពិសេសចំពោះសហគ្រាសធុនតូច និងមធ្យម ក្នុងស្ថានភាព សេដ្ឋកិច្ចបច្ចុប្បន្ន។

**ទី៥-សមាហរណកម្មកម្ពុជាក្នុងតំបន់ និងពិភពលោក**

រាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាបន្តជំរុញការធ្វើសមាហរណកម្មប្រទេសកម្ពុជា ទៅក្នុងតំបន់ និង ពិភពលោក ដោយចូលរួមយ៉ាងសកម្មក្នុងការអនុវត្តន៏កម្មវិធីនានា ដែលបានព្រមព្រៀងគ្នាកន្លងមក និង កិច្ចសហប្រតិបត្តិការនានា ដែលកំពុងពិភាក្សានៅពេលបច្ចុប្បន្ន និងនៅពេលអនាគត។ ក្នុងកិច្ចការនេះ យើងត្រូវបន្តខិតខំទាញយកផលប្រយោជន៏សំរាប់ប្រទេសកម្ពុជា នូវច្រកចូលទីផ្សារសំរាប់ផលិតផលកម្ពុជា អាចនាំចូលទៅកាន់ទីផ្សារដ៏ធំធេងក្នុងតំបន់ និងក្នុង ពិភពលោក ដោយងាយស្រួល។ ជាមួយនេះ យើងត្រូវបន្តប្រឹងប្រែងប្រើឱ្យអស់លទ្ធភាពនូវជំនួយបច្ចេកទេសនានា ដែលដៃគូអភិវឌ្ឍន៏ផ្តល់ឱ្យ និងខិតខំស្វែងរកនូវជំនួយបច្ចេកទេសថ្មីៗថែមទៀត ដើម្បីពង្រឹងហេដ្ឋារចនាសម្ព័ន្ធ សមត្ថភាពធនធានមនុស្ស ស្ថាប័នរដ្ឋ វិសយ័ឯកជន និងសមត្ថភាព ផលិត និង ផ្គត់ផ្គង់របស់យើង។

មុននឹងបញ្ចប់ ខ្ញុំសូមឆ្លៀតយកឱកាសនេះ ថ្លែងអំណរគុណជាថ្មីម្តងទៀត ចំពោះឯកឧត្តម លោកជំទាវ លោកស្រី នៃក្រសួង ស្ថាប័នពាក់ពន្ធ័ អង្គការក្រៅរដ្ឋាភិបាល ផ្នែកវិស័យឯកជន និងស្ថាប័នផ្សេងៗទៀត ដែលបានគាំទ្រ និងជួយជំរុញវិស័យពាណិជ្ជកម្មកម្ពុជាឱ្យមានសន្ទុះរីកចំរើនយ៉ាងឆាប់រហ័ស ហើយវិភាគទានទាំងនេះ គឺជាការចូលរួមក្នុង ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៏ស្របតាមគោលនយោបាយយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។

ខ្ញុំសូមប្រសិទ្ធពរបវរមហាប្រសើរ ជូនចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី សូមប្រកប ដោយវិបុលសុខ សុខភាពល្អបរិបូរណ៍ សុភមង្គល និងទទួលបានជោគជ័យគ្រប់ភារកិច្ច។

**ខ្ញុំសូមប្រកាសបើកសន្និបាតបូកសរុបលទ្ធផលការងារពាណិជ្ជកម្មឆ្នាំ២០០៩ និងលើកទិសដៅការងារពាណិជ្ជកម្មឆ្នាំ២០១០ ចាប់ពីពេលនេះតទៅ !**

**សូមអរគុណ !**